ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

TRUST REGULATOR

**និយ័តករបរធនបាលកិច្ច**

លេខ: ០១៧/២៤ ន.ប.ធ./ឥ.ស.៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការទទួលចុះឈ្មោះចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្ត ក្នុងវិស័យបរធនបាលកិច្ច លើកទី៥

និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិ ក្នុងវិស័យបរធនបាលកិច្ច សម្រាប់ក្រុមហ៊ុនបរធនបាល, ក្រុមបរធនបាលនៃបរធនបាលកិច្ចហិរញ្ញវត្ថុ, បរធនបាលរូបវន្តបុគ្គលឯករាជ្យ, ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច, ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច, ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច និងសាធារណជនទាំងអស់មេត្តាជ្រាបថា÷ **ន.ប.ធ.** នឹងចាប់ផ្តើមទទួលពាក្យចុះឈ្មោះចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្ត ក្នុងវិស័យបរធនបាលកិច្ច លើកទី៥ **ចាប់ពីថ្ងៃជូនដំណឹងនេះតទៅរហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤។** អាស្រ័យហេតុនេះ បុគ្គលដែលបម្រើការងារក្នុងវិស័យបរធនបាលកិច្ច និងសាធារណជន ដែលមានបំណង ឬត្រូវបានតម្រូវឱ្យចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ លើកទី៥ និងបុគ្គលជិតផុតសុពលភាពដែលបានចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ (វគ្គទី១ វគ្គទី២ និងវគ្គទី៣) ដែលត្រូវចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្តទាំងអស់ សូមអញ្ជើញមកចុះឈ្មោះ និងបង់ថ្លៃចូលរួមវគ្គបណ្តុះបណ្តាលនេះនៅនិយ័តករបរធនបាលកិច្ច ដែលមានទីតាំងនៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ(ជាន់ទី៨) អាសយដ្ឋានផ្លូវ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមរយៈលេខទូរសព្ទតេលេក្រាម ០៩៦ ៧៤០ ៨៨៩៣/ ០៧៧ ២៧៨ ០១៩/ ០១០ ៤១៥ ៥២០ ឬអ៊ីមែល÷ info@trustregulator.gov.kh។

**បញ្ជាក់÷** ចំពោះវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្ត ក្នុងវិស័យបរធនបាលកិច្ច លើកទី៥ នេះ ត្រូវបង់ថ្លៃចូលរួមចំនួន **៨០០,០០០៛ (ប្រាំបីរយពាន់រៀល)** ក្នុងមួយនាក់។ **ក្នុងករណីបុគ្គលដែលចុះឈ្មោះក្រោយកាលបរិច្ឆេទដែលបានកំណត់ត្រូវបង់ថ្លៃចូលរួមចំនួន ១,០០០,០០០៛ (មួយលានរៀល)**។ សូមទាញយកពាក្យស្នើសុំតាមរយៈតំណភ្ជាប់មួយនេះ÷ https://shorturl.at/fqJW4 ឬតាមរយៈ QR Code ខាងក្រោម។

**សម្គាល់÷** ចំពោះកាលបរិច្ឆេទក្នុងការរៀបចំវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្ត ក្នុងវិស័យបរធនបាលកិច្ច លើកទី៥ **ន.ប.ធ.** នឹងជម្រាបជូនតាមក្រោយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងបុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិទាំងអស់ជ្រាបជាព័ត៌មាន។

ថ្ងៃ ព្រហស្បតិ៍ ១៤កើត ខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០២៤

**និយ័តករបរធនបាលកិច្ច**

**សូមទាញយកពាក្យស្នើសុំនៅទីនេះ**